**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ២ដង ក្នុង ១ខែ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា កន្លងទៅ រោងចក្រ សហគ្រាស តែងតែបើកផ្តល់ប្រាក់ឈ្នួលប្រចាំខែដល់កម្មករនិយោជិតរបស់ខ្លួន នៅចន្លោះថ្ងៃទី០១ ដល់ថ្ងៃទី០៧ នៃខែបន្ទាប់ ដោយសាររោងចក្រ សហគ្រាស ត្រូវគណនាចំនួនថែមម៉ោង ចំនួនផលិតផលដែលសម្រេចបាន និងប្រាក់លើកទឹកចិត្តផ្សេងៗទៀតក្នុងខែនីមួយៗ។ ដោយឡែកចាប់ពីខែមករា ឆ្នាំ២០១៩ នេះតទៅ រោងចក្រ សហគ្រាស នឹងបើកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០% ឱ្យដល់កម្មករនិយោជិតនៅចន្លោះពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ នៃខែនីមួយៗ និងបើកផ្តល់ប្រាក់ឈ្នួលសរុបដែលនៅសល់ឱ្យដល់កម្មករនិយោជិតចន្លោះពីថ្ងៃទី០១ ដល់ថ្ងៃទី០៧ នៃខែបន្ទាប់។

គិតត្រឹមរសៀលថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការពិនិត្យតាមដានអំពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត២ដង ក្នុង១ខែ នេះ ឃើញថា រោងចក្រ សហគ្រាស ចំនួន ៨១% បាននឹងកំពុងអនុវត្តការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន២ដង ក្នុង១ខែ ស្របតាមប្រកាសលេខ៤៤២ ក្នុងនោះ ៖

១-រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ប្រមាណ៥០% អនុវត្តការបើកប្រាក់ឈ្នួលលើកទី១ នៅចន្លោះថ្ងៃទី១៦ ដល់ថ្ងៃទី១៩ នៃខែមករានេះ និងបើកលើកទី២ នៅចន្លោះថ្ងៃទី០១ ដល់ថ្ងៃទី០៧ នៃខែបន្ទាប់។

២-រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ប្រមាណ២៥% អនុវត្តការបើកប្រាក់ឈ្នួលលើកទី១ នៅថ្ងៃទី១៦ ខែមករា នេះ និងបើកលើកទី២ នៅថ្ងៃទី០១ នៃខែបន្ទាប់។

៣-រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ប្រមាណ២៥% អនុវត្តការបើកប្រាក់ឈ្នួលលើកទី១ នៅថ្ងៃទី២៥ ខែមករា នេះ និងលើកទី២ នៅថ្ងៃទី១០ នៃខែបន្ទាប់។

ចំពោះ រោងចក្រ សហគ្រាស ដែលកំពុងរៀបចំអនុវត្ត ក្រសួងនឹងធ្វើការត្រួតពិនិត្យ ដើម្បីជំរុញឱ្យអនុវត្ត ក្នុងករណីមិនអនុវត្ត នឹងត្រូវផាកពិន័យតាមច្បាប់ស្តីពីការងារ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១១កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៩